# NEWS RELEASE

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## លោកស្រី ភីឡៃ ស្វាគមន៍ការតែងតាំងប្រធានថ្មី ទទួលបន្ទុកសិទ្ធិមនុស្ស អ.ស.ប

**ក្រុងហ្សឺណែវ** (១៧ មិថុនា ២០១៤) - ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស លោកស្រី ណាវី ភីឡៃ កាលពីថ្ងៃអង្គារនេះ បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះការតែងតាំងរបស់មហាសន្និបាត អ.ស.ប លោក ហ្សៃដ រ៉ាអាដ ហ្សៃដ អាល់ ហ៊ូស្សេន ស្នងតំណែងរបស់លោកស្រី នៅពេលដែលអាណត្តិរបស់លោកស្រី ភីឡៃ បានមកដល់ទីបញ្ចប់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៤ ខាងមុខនេះ។
អគ្គលេខាធិការ បានស្នើឈ្មោះ លោក ហ្សៃដ រ៉ាអាដ ហ្សៃដ អាល់ ហ៊ូស្សេន ដែលបច្ចុប្បន្ន លោកជាតំណាងអចិន្ត្រៃយ៍នៃហ្ស៊កដានី ប្រចាំអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក សម្រាប់អាណត្តិមួយ ដែលមានរយៈពេលបួនឆ្នាំ ជាឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយមហាសន្និបាតនៅថ្ងៃច័ន្ទនេះ។
" លោក ហ្សៃដ រ៉ាអាដ ហ្សៃដ អាល់ ហ៊ូស្សេន នាំមកនូវបទពិសោធន៍ជាច្រើនឆ្នាំលើឆាកអន្តរជាតិ ដល់ការិយាល័យឧត្តមស្នងការ រួមទាំងជំនាញដ៏ច្រើនសន្ធឹកសន្ធាប់ លើបញ្ហាសិទ្ធិមនុស្សផ្សេងៗ និងពិសេស ក្នុងវិស័យយុត្តិធម៌អន្តរជាតិ និងការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព" លោកស្រី ភីឡៃ មានប្រសាសន៍។

"ខ្ញុំសូមអបអរសាទរការសម្រេចចិត្តរបស់អគ្គលេខាធិការ និងមហាសន្និបាត តែងតាំងគាត់ជាអ្នកស្នងតំណែងរបស់ខ្ញុំ ក្នុងនាមជាប្រធានការិយាល័យទទួលបន្ទុកការពារសិទ្ធិមនុស្សគ្រប់យ៉ាងរបស់មនុស្សគ្រប់រូបនៅគ្រប់ទីកន្លែង។ ខ្ញុំសង្ឃឹមរីករាយ នឹងធ្វើការផ្ទេរប្រគល់អាណត្តិការងារមួយគ្មានពីរ និងពិសេសនេះ ជូនគាត់ ហើយខ្ញុំជឿជាក់ថា គាត់នឹងទទួលអនុវត្តបន្តនូវតួនាទីរបស់ឧត្តមស្នងការសិទ្ធិមនុស្ស ដោយភាពស្មោះត្រង់ មិនលាក់លៀម និងការយកចិត្តទុកដាក់ ដូចបានបង្ហាញនៅក្នុងអាជីពរបស់គាត់កន្លងមក"។

លោក **ហ្សៃដ រ៉ាអាដ ហ្សៃដ អាល់ ហ៊ូស្សេន** នឹងក្លាយជាឧត្តមស្នងការទីប្រាំមួយ ចាប់តាំងពីការិយាល័យនេះ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ មក។ បុព្វាធិការនិងបុព្វាធិការីរបស់គាត់ រួមមាន៖ លោក **ជូសេ អាយ៉ាឡា ឡាស់សូ** (អេក្វាឌ័រ ១៩៩៤-១៩៩៧) លោកស្រី **ម៉ារី រ៉ូប៊ីនសុន** (អៀរឡង់ ១៩៩៧- ២០០២) លោក **សឺជីអូរ វៀរ៉ា ឌឺ មេឡូ** (ប្រេស៊ីល ២០០២- ២០០៣) លោកស្រី **ល្វីស អាប៊ួរ** (កាណាដា ២០០៤-២០០៨) និងពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៤ ហើយដែលនៅកំពុងកាន់តំណែងនាពេលបច្ចុប្បន្ននេះ គឺលោកស្រី **ណាវី ភីឡៃ** (អាហ្វ្រិកខាងត្បូង) ។

ចប់

*ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស មានបុគ្គលិកប្រមាណជា ១.១០០ នាក់ នៅទីស្នាក់ការកណ្តាលរបស់ខ្លួន ប្រចាំទីក្រុងហ្សឺណែវ និងមានវត្តមានក្នុងប្រទេសចំនួន ៦៥ នៅជុំវិញពិភពលោក។*

*ដើម្បីស្វែងយល់បន្ថែមទៀត អំពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស សូមចូលទៅកាន់ http://www.ohchr.org*

*សំរាប់ព័ត៌មានបន្ថែម ឬសំណើរសុំព័ត៌មានផ្សេងៗ សូមមេត្តាទាក់ទងមក៖ លោក Rupert Colville តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧៦៧ + ៤១ ២២ ៩១៧ ៩៧៦៧ / ឬតាមរយៈអ៊ីម៉េល rcolville@ohchr.org) ឬ Ravina Shamdasani តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៧៦៩ + ៤១ ២២ ៩១៧ ៩៧៦៩ / ឬតាមរយៈអ៊ីម៉េល rshamdasani@ohchr.org) ឬ Cécile Pouilly តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣១០ +៤១ ២២ ៩១៧ ៩៣១០ / ឬតាមរយៈអ៊ីម៉េល cpouilly@ohchr.org)*

--------------------------------------------------------

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង លើបណ្តាញព័ត៌មានសង្គម ៖**

ហ្វេសប៊ុក៖ https://www.facebook.com/unitednationshumanrights

ទ្វីតធឺ៖ http://twitter.com/UNrightswire

ហ្គោហ្គីល៖ **Google+** gplus.to/unitednationshumanrights

យូធូប៖ http://www.youtube.com/UNOHCHR

បរិយាយសាច់រឿង ៖ http://storify.com/UNrightswire

ពិនិត្យសន្ទស្សន៍សិទ្ធិមនុស្សជាសកល: http://uhri.ohchr.org/en